ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប

## កំណត់ហេតុ

## កិច្ចប្រជុំជំនាញពាក់ព័ន្ធ និងការរៀបចំគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី ស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែឧសភា ថ្ងៃទីដប់ពីរ វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបើកកិច្ចប្រជុំជំនាញពាក់ព័ន្ធ និងការរៀបចំគោលការណ៍ណែនាំ **ស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស** ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង អង្គភាពពាក់ព័ន្ធ មួយចំនួនដូចជា៖

| | | |
|---|---|---|
| ១. ឯ.ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ២. ឯ.ឧ | ប៉ែន ពេជ្រសាលី | អគ្គនាយក នៃអគ្គនាយកដ្ឋាន ក្រសួងយុត្តិធម៌ |
| ៣. ល.ជំទាវ | ឱ វ៉ាន់ឌីន | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល |
| ៤. ឯ.ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥ ល.ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦. ឯកឧត្តម | អ៊ូច ចាន់ណូរ៉ា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៧. លោកជំទាវ | វ៉ន សិរីលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៨. ឯ.ឧ.ឯក | ហាស់ ប៉េងឡុង | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ៩. ឯ.ឧ ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១០. ល.ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ១១. ល.វ.ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប គ.ជ.ប.ជ |
| ១២. លោក | យឹម សំអុល | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ១៣. ល.វ.ឯក | ឆាន វុធ | ប្រធានការិយាល័យ នៃ នាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ១៤. លោក | ណុប រដ្ឋា | ប្រធានការិយាល័យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ១៥. លោក | ចាប សៀកឆាយ | អនុប្រធានវិទ្យាស្ថានជាតិ សុខភាពសាធារណៈ |

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញចូលរួមប្រជុំនាឱកាសនេះ។ លោកជំទាវ បានមានប្រសាសន៍ទាក់ទង សជណ លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ នាពេលកន្លងមកយើងបានជួបប្រជុំគ្នាម្តងរួចមកហើយកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ តែលទ្ធផលយើងពុំទាន់ទទួលបានអ្វីនៅឡើយទេ ដូច្នេះដើម្បីដោះស្រាយបាតុភាព នៃការពពោះជំនួសក្នុងដំណាក់កាលនេះ គិតចាប់ពីពេលផ្សាយដំណឹងរហូតដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) សូមដាក់ចេញនូវ **គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណីពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស** មួយចំនួនដើម្បីជួយសម្រួលដល់ការស្នើសុំពីឪពុករបស់ទារក ដែលជាជនបរទេស ហើយមានបំណងយកកូនរបស់ខ្លួនទៅចិញ្ចឹមបីបាច់នៅឯប្រទេសរបស់ខ្លួននោះ មានដូចជា៖

**១.ជនបរទេសដែលអះអាងថាជាឪពុក**

ត្រូវធ្វើការស្នើសុំតាមរយៈស្ថានទូតសាមី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដោយសំណុំលិខិតឯកសារនីមួយៗ មានសុពលភាពយ៉ាងតិច ០៦ខែ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។ សំណុំលិខិត ឯកសារទាំងអស់ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបន្តនីតិវិធី។

**២.ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ទទួលពាក្យស្នើសុំ ដែលបញ្ជូនពីស្ថានទូតសាមីរបស់អ្នកស្នើសុំប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយ សំណុំ លិខិតឯកសារពីភាគីអ្នកទទួលពពោះផងដែរ។ រួចក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចេញ សជណ ស្តីពីសំណុំលិខិត ឯកសារ ដែលស្នើសុំទាំងអស់នេះ បញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីបន្តនីតិវិធី។

**៣.តុលាការ**

ទទួលពាក្យសុំពីសាមីខ្លួនជាសហព័ទ្ធរបស់ស្ត្រីពពោះ(បើមាន) ស្តីពីការបដិសេធបិតុភាពលើទារក ពាក្យស្នើសុំបិតុភាពពីបុរសជនបរទេសដោយសំអាងលើលិខិតបញ្ជាក់លទ្ធផលពិសោធន៍ DNA ពីវិទ្យាស្ថាន ឬមន្ទីរពេទ្យឯកទេស ហើយធ្វើការវិនិច្ឆ័យដើម្បីចេញជាសាលក្រម។ល។

**៤.ក្រសួងមហាផ្ទៃ**

ទទួលសំណុំ លិខិត ឯកសារ ដែលបានបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ភ្ជាប់ដោយ សជណ ដើម្បីពិនិត្យលើលក្ខខ័ណ្ឌសមស្របទាំងឡាយដែលគួរអនុញ្ញាតិ ឬត្រូវបំពេញបន្ថែមរួចចេញលិខិតឲ្យ៖

+អគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម

+អគ្គនាយកដ្ឋាន អន្តោប្រវេសន៍

ក្រោយពីបានលើកបង្ហាញនូវគោលការណ៍ ណែនាំស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណីពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស ដល់អង្គប្រជុំរួចមក **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ មានប្រសាសន៍សុំឲ្យតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានវត្តមាននាពេលនេះលើកឡើងជាមតិយោបល់ ធ្វើការកែសម្រួលបែបបទ និងនីតិវិធីដែលបានបង្ហាញនេះត្រង់ចំណុចណាខ្លះ?

**-ប្រសាសន៍ ឯ.ឧ ម៉ែន ពៅជ្រសាលី** អគ្គនាយក នៃអគ្គនាយកដ្ឋាន ក្រសួងយុត្តិធម៌

សជណ លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ អំពីការស្នើសុំគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួសដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេសនោះ បើតាមការពិនិត្យសង្កេតឃើញថា ករណីនេះជាប់ពាក់ព័ន្ធចំពោះស្ត្រីដែលមានបំណងអាពាហ៍ពិពាហ៍រួចហើយ សម្រាប់ស្ត្រីនៅលីវពុំ

មានអ្វីស្មុគស្មាញនោះទេ។ ដូចនេះចំពោះស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ កូនដែលកើតមកត្រូវកំណត់ថា ជាកូនរបស់ប្តី នៃស្ត្រីពពោះ អ៊ីចឹងឪពុកដែលជាម្ចាស់មេជីវិតចាំបាច់ត្រូវប្តឹងទៅតុលាការដើម្បីទាមទារបិតុភាពលើទារកនោះតាមផ្លូវច្បាប់ដោយបង្ហាញលទ្ធផលពិសោធន៍ DNA ថាពិតជាឪពុករបស់ទារកនោះមែន។ ប៉ុន្តែ ឪពុកដែលជាអ្នកស្នើសុំនោះត្រូវតែមានសហព័ទ្ធ(គ្រួសារ) ទើបយើងមានការអនុញ្ញាតឲ្យគាត់យកចេញទៅបាន។ពាក់ព័ន្ធករណីនេះដែរប្រសិនបើស្ត្រីពពោះនោះពុំបានយល់ព្រមឲ្យទារកទៅឪពុកដែលជាអ្នកស្នើសុំ គឺមានតែតុលាការមួយគត់ជាអ្នកសម្រេច។ ដូច្នេះចាំបាច់អ្នកទាំងពីរត្រូវមានការឯកភាពគ្នាសិន។ បើយើងចង់ដឹងច្បាស់មើលក្រមរដ្ឋប្បវេណីមាត្រា៩៨៨ គឺបញ្ជាក់ និងចែងច្បាស់ហើយ។ ចំពោះរយៈពេល ០៩ខែ ១០ថ្ងៃ គឺយើងចាប់គិតពីថ្ងៃចេញ សជណ ដោយមានសំបុត្រពេទ្យបញ្ជាក់ច្បាស់លាស់ពីពេលវេលារបស់ទារកដែលបានកើតចេញមក។ ដោយឡែកចំពោះសុពលភាព លិខិតថ្កោលទោសសម្រាប់កម្ពុជាយើងកំណត់ត្រឹមរយៈពេល ០៣ខែ តែជនបរទេសគឺសុពលភាពលិខិតថ្កោលទោសរបស់គេមានរយៈពេលច្រើនជាងយើង។ ចំពោះតុលាការតាមបណ្តាខេត្តពុំចាំបាច់អនុវត្តនីតិវិធីពាក់ព័ន្ធករណីពពោះជំនួសនេះទេ ទុកឲ្យ ឬប្រគល់ឲ្យតុលាការរាជធានីភ្នំពេញតែមួយជាអ្នកធ្វើការសម្រេចបានហើយ។

-**ឯកឧត្តម អ៊ុច ចាន់ណូរ៉ា អគ្គនាយករង** នៃអគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម

ការចុះសំបុត្រកំណើតរបស់ទារកដែលមានឪពុកម្តាយជាជនជាតិខ្មែរ ឬប្តីប្រពន្ធពីនាក់មានម្នាក់ជាជនជាតិខ្មែរ គឺយើងអនុញ្ញាតឲ្យចុះបញ្ជីជាតិបានទោះបីជាកូននោះមាន ឬអត់មានខាន់ស្លាក៏ដោយ កូននោះត្រូវចុះសំបុត្រកំណើតជាខ្មែរ។ ប្រសិនបើចង់ឲ្យកូននោះដូរសញ្ជាតិជាបរទេសវិញ លុះត្រាតែមានសាលក្រមរបស់តុលាការទើបយើងផ្តល់សញ្ជាតិឲ្យកូននោះជាសញ្ជាតិបរទេសបាន ហើយកូននោះគឺមានសញ្ជាតិពីរ ខ្មែរមួយ និងបរទេសមួយ។ ចំពោះបែបបទ និងនីតិវិធីសម្រាប់អនុវត្ត សជណ លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ គួរកែសម្រួលចំណុចទី០១(ជនបរទេសដែលអះអាងថាជាឪពុក, លិខិតផ្តល់សញ្ជាតិពីអាជ្ញាធរប្រទេសសាមី(អ្នកស្នើសុំ) និងការផ្ទេរសិទ្ធិអាណាព្យាបាលលើទារកទៅជនបរទេស ហើយគួរសម្រួលចំណុចទី៣(តុលាការ) ដាក់ទៅចំណុចទី២វិញ ព្រោះករណីនេះអ្នកស្នើសុំដាច់ខាតត្រូវតែឆ្លងកាត់តុលាការ ដោយផ្អែកលើសំណើសុំទារកតាមរយៈស្ថានទូតរបស់គេរួចមក(សំណុំឯកសារបញ្ជាក់ពីទូត)។

-**លោក ណុប រដ្ឋា** ប្រធានការិយាល័យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំណុំលិខិត និងឯកសាររបស់អ្នកស្នើសុំទារក តាមការពិនិត្យមើលឃើញថា ចេញមកពីស្ថានទូតរបស់ខ្លួនមុនចូលមកក្រសួងការបរទេស ពេលចូលមកដល់ក្រសួងការបរទេសហើយ ពិនិត្យឃើញថាត្រឹមត្រូវតាមនីតិវិធីទើបក្រសួងការបរទេស ធ្វើការបញ្ជូនមកក្រសួងមហាផ្ទៃ អនុវត្តនីតិវិធីបន្តទៀត។ ប៉ុន្តែសុពលភាពលិខិតឯកសារពាក់ព័ន្ធខ្លះ ហួសសុពលភាពក្នុងការបំពេញបែបបទ។ ចំពោះករណីនេះអាចចេញសាលក្រមទាំងពីរ ឬយ៉ាងណា?

-**ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

យើងជួបប្រជុំថ្ងៃនេះ គឺផ្តោតសំខាន់ទៅលើការកែសម្រួល លើគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីដែល **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានលើកបង្ហាញដើម្បីធ្វើការសម្រេច។ តាមប្រសាសន៍ ឯកឧត្តម កើត រិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ក្នុងកិច្ចប្រជុំពិភាក្សាស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ បានបញ្ជាក់ច្បាស់ថា ករណីនេះគឺមានតែតុលាការតែមួយគត់ ដែលមានសិទ្ធិសម្រេចលើបញ្ហានេះ។

-**ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម ទិរៈ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស បានចង្អុលបង្ហាញពីតួនាទីភារកិច្ចរបស់ក្រសួង អង្គភាពពាក់ព័ន្ធស្រេចហើយ យើងគ្រាន់តែកែ

សម្រួលឃ្លាខ្លះៗ កុំវែងពេក និងពិបាលយល់។ ក្រសួងយុត្តិធម៌គួរជូនដំណឹងដល់សាលាដំបូងរាជធានី-ខេត្ត ដែលមានការពាក់ព័ន្ធករណីពពោះជំនួស នៅដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីអនុវត្តតាមនីតិវិធី។

-**លោកជំទាវ វ៉ែន សិរិលក្ខិណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ពាក់ព័ន្ធលើលិខិតស្នាម(លិខិតថ្កោលទោស) សម្រាប់កម្ពុជាយើងសុពលភាព មានរយៈពេលតែ ០៣ខែប៉ុណ្ណោះ ខុសពីប្រទេសគេ មានសុពលភាពហូតដល់ ០១ឆ្នាំ ទៅ ០២ឆ្នាំ ឯណោះ។ តើយើងត្រូវគិតយ៉ាងណាដើម្បីឲ្យមានលក្ខណៈស៊ីសង្វាក់គ្នា និងមានភាពងាយស្រួលនៅក្នុងការអនុវត្តតាមនីតិវិធី ក៏ដូចជាបង្កភាពងាយស្រួលដល់អ្នកស្នើសុំ?

-**ឯកឧត្តម ឧត្តមសេនីយ៍ទោ ធូ ម៉ានីវ៉ា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

សូមកែសម្រួលឃ្លា ត្រង់ចំណុច (ក) អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម៖ ចេញលិខិតបញ្ជាក់កំណើតជាថ្មីដែលប្តូរសញ្ជាតិរបស់ទារកពីសញ្ជាតិខ្មែរ ទៅជាសញ្ជាតិបរទេស តាមសេចក្តីរបស់តុលាការ និងលិខិតបញ្ជាក់ពីអាជ្ញាធរបរទេស គួរត្រូវកែសម្រួលថា៖ ចេញលិខិតបញ្ជាក់កំណើតជាថ្មីតាមសេចក្តីសម្រេចរបស់តុលាការ វិញ។

-**ឯកឧត្តម ឧត្តមសេនីយ៍ទោ ហាស់ ម៉េងឡុង** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

សម្រាប់ជំនាញរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ វិញពេលទទួលបាន សជណ របស់ក្រសួងមហាផ្ទៃអនុញ្ញាតឲ្យ គឺអគ្គនាយកដ្ឋានអន្តោប្រវេសន៍ រៀបចំធ្វើបែបបទទិដ្ឋាការចេញឲ្យសាមីអ្នកស្នើសុំនាំយកទារកចេញទៅក្រៅប្រទេសបានតាមផ្លូវច្បាប់។

ចុងបញ្ចប់ នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន **អចិន្ត្រៃយ៍** គ.ជ.ប.ជ បានស្នើសុំឲ្យគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំកែសម្រួលលើគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី ខាងលើតាមជំនាញរៀងៗខ្លួន ដើម្បីចូលប្រជុំពិភាក្សាគ្នាបន្តនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសែសិបប្រាំនាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ ឌិក_សត្យា

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប

**ឧត្តមសេនីយ៍ទោ. គង់_ពុទ្ធី**

បានឃើញ

18/05/17

**ជូ_ប៊ុនអេង**